**សុន្ទរកថាដោយឯកឧត្តមគូម៉ាម៉ារូ យូជិ**

**ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា ក្នុងឱកាសជប់លៀងជូនដំណើរនិងការចងបណ្តាញ**

**និស្សិតអាហារូបករណ៍ជប៉ុន**

**ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៥**

ជាបឋម ខ្ញុំសូមសម្តែងនូវគារវកិច្ចអំណរអរគុណយ៉ាងជ្រាលជ្រៅដល់ការចូលរួមក្នុងកម្មវិធីជប់លៀងយប់នេះ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តមពិតចំណាននូវវត្តមានរបស់ឯកឧត្តមក្នុងរាត្រីនេះនិងសូមអរគុណដល់ការគាំទ្រដ៏ថ្លៃថ្លាពីសំណាក់ក្រសួងរបស់ឯកឧត្តម។

រដ្ឋាភិបាលជប៉ុនបានផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាទៅសិក្សានៅប្រទេសជប៉ុនតាំងពីឆ្នាំ១៩៩២មក។ មាននិស្សិតកម្ពុជាជាង៩២០នាក់ហើយបានទៅសិក្សានៅប្រទេសជប៉ុនតាមរយៈគ្រោងការណ៍ផ្សេងៗរបស់រដ្ឋាភិបាលជប៉ុន។ ក្នុងចំណោមអាហារូបករណ៍ទាំងនោះ មានអាហាររូបករណ៍ “Monbuka gakusho” ត្រូវបានផ្តល់ដោយក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រនិងបច្ចេកវិទ្យារបស់ជប៉ុន។ កន្លងមកក្រោមគ្រោងការណ៍នេះមាននិស្សិតកម្ពុជាជាង ៥៧០នាក់ត្រូវបានអញ្ជើញទៅសិក្សានៅប្រទេសជប៉ុន។ នៅក្នុងគ្រោងការណ៍នេះគឺមាន៧កំរិត ដែលក្នុងនោះរួមមានថ្នាក់ក្រោយឧត្តមសិក្សា ថ្នាក់ឧត្តមសិក្សា ថ្នាក់មធ្យមសិក្សាបច្ចេកទេស  ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីអ្នកដឹកនាំវ័យក្មេង ថ្នាក់និស្សិតសិក្សាភាសាជប៉ុន និងថ្នាក់បណ្តុះបណ្តាលគ្រូបង្រៀន។

មានគ្រោងការណ៍សំខាន់ផ្សេងទៀតដែលមានឈ្មោះថា ជំនួយរដ្ឋាភិបាលជប៉ុនសម្រាប់អភិវឌ្ឍធនធានមនុស្ស (JDS)។ អង្គការ JICAជាស្ថាប័នអនុវត្តនូវគម្រោងការណ៍នេះ ហើញបានអញ្ជើញមន្ត្រីវ័យក្មេងរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានកម្ពុជាទៅសិក្សានៅប្រទេសជប៉ុន។ កន្លងមកគឺមានសិស្សច្រើនជាង៣២០នាក់ហើយដែលបានចូលរួម។

យើងមានសេចក្តីអំណររីករាយដែលអាហារូបករណ៍របស់រដ្ឋាភិបាលជប៉ុនមានប្រជាប្រិយភាពនៅប្រទេសកម្ពុជា។ នៅក្នុងឆ្នាំនេះមានសិស្សដាក់ពាក្យប្រលងអាហារូបករណ៍សរុបចំនួនជាង១៣០០នាក់នៅក្នុងកំរិតចំនួន៥។ ក្នុងនោះអ្នកដែលទទួលបានជោគជ័យទទួលបានអាហារូបករណ៍ថ្មីចំនួន៣៨នាក់គឺមានវត្តមាននៅរាត្រីនេះ។ តួរលេខនេះគឺមានកំណើនស្ទើរតែទ្វេរដងបើប្រៀបធៀបទៅនិងឆ្នាំមុន។ សិស្សដែលទទួលបានអាហាររូបករណ៍នៅយប់នេះគឺឆ្លងកាត់ការប្រលងនៅប្រទេសកម្ពុជា ក៏ដូចជាការប្រកួតប្រជែងបន្ថែមទៀតជាមួយនិងសិស្សនៅប្រទេសដទៃ។ ខ្ញុំសូមកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់គ្នាក្នុងការទទួលបាននូវជោគជ័យនេះ ។

ខ្ញុំជឿថាបរិស្ថានសិក្សានៅប្រទេសជប៉ុន នឹងផ្តល់ឱកាសដ៏អស្ចារ្យមួយដល់អ្នកទទួលអាហាររូបករណ៍ នូវជំនាញនិងចំណេះដឹង ដែលអាចក្លាយទៅជាទ្រព្យដ៏សំខាន់មួយសម្រាប់អនាគតរបស់អ្នក។

ខ្ញុំសូមអោយអ្នកទាំងអស់គ្នាដែលជានិស្សិតអាហាររូបករណ៍ទាំងអស់មានមហិច្ឆិតាទទួលបាននូវជំនាញនិងចំណេះដឹងទាំងនេះនៅប្រទេសជប៉ុន ហើយខ្ញុំក៏មិនមានមន្ទិលនោះទេថាអ្នកនឹងមានភាពភ្ញាក់ផ្អើលនៅក្នុងថ្ងៃអនាគតថាតើអ្នកនឹងទទួលបានូវគុណប្រយោជន៍អ្វីខ្លះពីបទពិសោធនៅប្រទេសជប៉ុន។ ខ្ញុំសង្ឃឹមថាសមាគមអតីតនិស្សិតកម្ពុជាមកពីប្រទេសជប៉ុននឹងធានាអះអាងចំពោះបទពិសោធនេះ។

បើនិយាយពីទំនាក់ទំនងនៃប្រទេសយើងទាំងពីរវិញយើងបានឃើញអំពីការរីកចម្រើននិងភាពស៊ីជម្រៅនៃទំនាក់ទំនងយ៉ាងឆាប់រហ័ស។ ប្រទេសយើងទាំងពីរបានសម្រេចនូវការរីកចម្រើន និងការអភិវឌ្ឍទំនាក់ទំនងទ្វេរភាគីយ៉ាងជ្រាលជ្រៅនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះទាំងវិស័យសាធារណៈនិងវិស័យឯកជនរួមទាំងពាណិជ្ជកម្ម វប្បធម៌ សិក្សាធិការ បម្លាស់ប្តូរមនុស្សនិងមនុស្ស ជាដើម។ នៅក្នុងស្ថានភាពនេះ ចំពោះ

អ្នកដែលបានសិក្សានៅប្រទេសជប៉ុននឹងត្រូវបានសង្ឃឹមថានឹងជាអ្នកដើរតួនាទីយ៉ាងសំខាន់ ហើយពួកគេក៏នឹងត្រូវរំពឹងទុកថានឹងក្លាយទៅជាអ្នកដឹកនាំលើជំនាញដែលពួកគេបានជ្រើសរើស។ ខ្ញុំក៏មានក្តីសង្ឃឹមខ្ពស់ថាអ្នកនឹងដើរតួនាទីជាស្ពានមិត្តភាពដ៏រឹងមាំរវាងប្រទេសយើងទាំងពីរ។

ក្នុងរាត្រីនេះយើងមានភ្ញៀវជាច្រើន។ យើងមានអតីតនិស្សិតអាហារូបករណ៍មកពីប្រទេសជប៉ុន។ ចំពោះសហាគមន៍ជនជាតិជាតិជប៉ុនវិញនោះគឺយើងមានទាំងសមាគមន៍ជនជាតិជប៉ុន និងសមាគមន៍ពាណិជ្ជកម្មជប៉ុននៅប្រទេសកម្ពុជា។ វាជាឱកាសដ៏រីករាយបំផុតប្រសិនបើពីធីជប់លៀងនេះផ្តល់ឱកាសដ៏ល្អដល់អ្នកទាំងអស់គ្នាអោយបានស្គាល់គ្នា និងចងបណ្តាញជាមួយគ្នាទៅវិញទៅមកផងដែរ។

ជាថ្មីម្តងទៀត នៅក្នុងឱកាសនេះខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងអប់រំយុវជននិងកីឡាក្នុងការបន្តជួយជ្រោមជ្រែងដល់កម្មវិធីអាហារូបករណ៍នេះរួមទាំងការជួយក្នុងការជ្រើសរើសនិស្សិតអាហារូបករណ៍។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់សមាគមន៍អតីតនិស្សិតមកពីប្រទេសជប៉ុនដល់ការរួមចំណែកក្នុងការជ្រើសរើសបេក្ខជនផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសូមជូនពរអោយសិស្សអាហារូបករណ៍ថ្មីទាំង៣៨នាក់ ទទួលបាននូវជោគជ័យក្នុងការសិក្សា និងទទួលបានសុខភាពល្អនៅប្រទេសជប៉ុន។ ខ្ញុំក៏សូមជូនពរដល់ភ្ញៀវចូលរួមទាំងឡាយដែលមានសណ្តានចិត្តចូលរួមក្នុងកម្មវិធីជប់លៀងនារាត្រីនេះ។

សូមអរគុណ។